# ឯកសារទស្សនទាន

# វេទិកាស្តីពី អភិបាលកិច្ច គណនេយ្យភាព និងតម្លាភាពសម្រាប់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា

## ក្រោមប្រធានបទ

## "លើកកម្ពស់អភិបាលកិច្ច និងការអនុលោមតាមច្បាប់ នៃអង្គការសង្គមស៊ីវិល"

ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ ពីម៉ោង ៨:00-0៤:៣០
នៅ អគារដាយកូនៀ ទីតាំងផ្ទះលេខ ១៩-២១ ផ្លូវ ៣៣០ បឹងកេងកងIII ខ័ណ្ឌចំការមន ភ្នំពេញ
(ទូរស័ព្ទលេខ ០២៣ ៤២៦ ២៨៨/ ០២៣២១៨១៨៩)

## I. សាវតារ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) គឺជាអង្គការសមាជិកភាពមួយដែលធំ និងមានវ័យចំណាស់ជាងគេនៅក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៩០មក អង្គការ គ.ស.ក បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ វិជ្ជាជីវៈ គណនេយ្យភាព អភិបាលកិច្ច និងការអភិវឌ្ឍប្រកបដោយប្រសិទ្ធិភាពសម្រាប់អង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការងារក្នុងវិស័យផ្សេងៗ នៅក្នុងប្រទេសកម្ពុជា។ អង្គការ គ.ស.ក បាន នឹងកំពុងអនុវត្តផែនការអភិបាលកិច្ចស្នូល (Governance Hub Program) ដំណាក់កាលទី៣ (GHP ២០១៧-២០២១) តាមរយៈកម្មវិធីសំខាន់ៗចំនួន៨រួមមាន: មជ្ឈមណ្ឌលសមាជិក វិមជ្ឈការ ភាពជាដៃគូប្រកបដោយបរិយាបន្ន និងអភិក្រមយកសិទ្ធិមនុស្សជាមូលដ្ឋាន ឬវិធីសាស្ត្រមិនបង្កទំនាស់ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ។

### ក. ប្រវត្តិសង្ខេបអំពី ប្រព័ន្ធវិញ្ញាបនបត្រស្តីពី អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ (ជីភីភី)

ចាប់តាំងពីឆ្នាំ ២០០៤មក អង្គការ គ.ស.ក បានអនុវត្តនូវកម្មវិធី អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ (ជីភីភី) ដែលគេទទួលស្គាល់ជាគម្រោងអភិបាលកិច្ច មានគោលបំណងលើកកម្ពស់អភិបាលកិច្ច គណនេយ្យភាព តម្លាភាព វិជ្ជាជីវៈ និងការអនុវត្តល្អនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ ជីភីភីត្រូវបានប្រតិបត្តិការជាប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្ត ឬប្រព័ន្ធវិញ្ញាបនបត្រជីភីភីផ្អែកលើបទដ្ឋានជីភីភី (ជាបទដ្ឋាន ឬក្រមរបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា)។ បទដ្ឋាននានាស្តីពីអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ គឺស្របតាមគោលការណ៍ទី ៥ ៦ និង៧ នៃគោលការណ៍អ៊ីស្តានប៊ុលស្តីពី ការអភិវឌ្ឍប្រកបដោយប្រសិទ្ធិភាពរបស់អង្គការសង្គមស៊ីវិល ដែលបានអនុម័តជាសកលនៅឆ្នាំ២០១០ និងស្របតាមគោលការណ៍សកល ស្តីពីគណនេយ្យភាពអង្គការសង្គមស៊ីវិលដែលជាគំនិតផ្តួចផ្តើមរួមអង្គការចំនួន ៩ ដែលជាអង្គការគ្រប់គ្រងបទដ្ឋានស្តីពីគណនេយ្យភាពនៅក្នុងពិភពលោក។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ វិញ្ញាបនបត្រ **ចំនួន ៩២ (៦៦ អង្គការ)** ត្រូវបានផ្តល់ជូនអង្គការជាតិ និងអន្តរជាតិដែលបានអនុលោមតាមបទដ្ឋានជីភីភី។ អង្គ

ការដែលទទួលបានវិញ្ញាបនបត្រជីភីភី បានដើរតួនាទីជាគំរូមួយយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកលើកកម្ពស់អភិបាលកិច្ច គណនេយ្យភាព តម្លាភាព និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ ដែលអនុលោមតាមបទដ្ឋាននានារបស់ ជីភីភី និងលក្ខខណ្ឌតម្រូវរបស់ប្រព័ន្ធវិញ្ញាបនបត្រស្ម័គ្រចិត្តនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល។ ប្រព័ន្ធវិញ្ញាបនបត្រ និងការប្រតិបត្តិតាមប្រព័ន្ធវិញ្ញាបនបត្រជីភីភី ក៏បានផ្តល់សារៈសំខាន់ដល់សហគមន៍ ម្ចាស់ជំនួយ រាជរដ្ឋាភិបាល និងក្រុមគោលដៅទាំងអស់។ លើសពីនេះទៅទៀត នៅក្នុងដំណើរការផ្តល់វិញ្ញាបនបត្របានជួយអង្គការអោយមានការអនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងធ្វើអោយអង្គការមានការសម្របសម្រួលខ្លួនក្នុងការផ្លាស់ប្តូរនូវការងារទាំងឡាយណា ដែលអាចមានឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានដល់ស្ថាប័ន។

ឆ្នាំនេះ ជីភីភីនឹងរៀបចំវេទិកាស្តីពីអភិបាលកិច្ច គណនេយ្យភាព និងតម្លាភាពសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាក្រោមប្រធានបទ ការលើកកម្ពស់អភិបាលកិច្ចល្អក្នុងអង្គការសង្គមស៊ីវិល និងការអនុលោមតាមច្បាប់។ ជាការកត់សំគាល់ ពិធីប្រគល់វិញ្ញាបនបត្រជីភីភីតែងភ្ជាប់ជាមួយវេទិការៀនសូត្រ ពិធីនេះមានបំណងផ្តល់វិញ្ញាបនបត្រជីភីភីជូនអង្គការដែលទើបទទួលបានវិញ្ញាបនត្រចំនួន ៥អង្គការ។ ដើម្បីអនុលោមទៅតាមច្បាប់ និងសារៈសំខាន់របស់ច្បាប់និមួយៗ វេទិការនេះនឹងលើកយកនូវច្បាប់ចំនួន ៣ រួមមានៈ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអង្គការ សមាគមមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

## ខ. សង្ខេបប្រធានបទសំខាន់ៗសម្រាប់វេទិកានេះ

### ១. ពិធីប្រគល់វិញ្ញាបនបត្រៈ

ពិធីប្រគល់វិញ្ញាបនបត្រនេះនឹងប្រារព្ធឡើងក្នុងគោលបំណង ដើម្បីផ្តល់កិត្តិយស ការកោតសរសើរ និងការលើកទឹកចិត្ត ដល់អង្គការចំនួន ៥ ដែលទើបទទួលបានវិញ្ញាបនត្រក្នុងឆ្នាំ២០១៨ ចំពោះការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ អភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាពនៅក្នុងអង្គការ។ នៅក្នុងពិធីដ៏វិសេសវិសាលនេះ នឹងត្រូវបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ឌី ច័ន្ទផល** ជាតំណាងមកពីក្រសួងមហាផ្ទៃ និងសមាជិក គណៈកម្មាធិការអនុវត្តក្រុម។

### ២. បទដ្ឋានសកលសម្រាប់គណនេយ្យភាពអង្គការសង្គមស៊ីវិល

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) និងអង្គការចំនួន ៩មកពីបណ្តាប្រទេសផ្សេងៗនៅលើសកលលោកដែលមានបទពិសោធន៍នៅក្នុងកិច្ចការគ្រប់គ្រងក្រមបទដ្ឋានអង្គការមិនមែនរដ្ឋាភិបាល បានរួមគ្នាតាក់តែងបទដ្ឋានសកលសម្រាប់គណនេយ្យភាពអង្គការសង្គមស៊ីវិល។ បទដ្ឋានសកលនេះបានដកស្រង់ចេញពីគោលការណ៍អ៊ីស្តានប៊ុល និងបទពិសោធន៍ដែលទាក់ទងនឹងគណនេយ្យភាពពីបណ្តាទ្វីបជាច្រើនរួមមានៈ ទ្វីបអាព្រិច អាស៊ី អូស្ត្រាលី អ៊ឺរ៉ុប អាមេរិចខាងជើង អាមេរិចឡាទីន និងការីបប៊ីន អង្គការដែលមកពីទ្វីបទាំងនេះបានធ្វើការរួមគ្នារយៈពេល២ឆ្នាំ ដើម្បីតាក់តែងបទដ្ឋានសកល ព្រមទាំងចែករំលែកការយល់ដឹងអំពីគណនេយ្យភាព។ បទដ្ឋានសកលរួមមានសេចក្តីប្តេជ្ញាចិត្តចំនួន១២ និងអមដោយសកម្មភាពគន្លឹះៗ ដែលអង្គការសង្គមស៊ីវិលសន្យា និងប្តេជ្ញាអនុវត្តតាមដើម្បីគណនេយ្យភាព។ សេចក្តីប្តេជ្ញាចិត្តត្រូវបានចែកចេញជា៣ ជំពូកៈ វត្ថុបំណងដែលអង្គការសង្គមស៊ីវិលចង់សម្រេចបាន វិធីសាស្រ្តដើម្បីផ្លាស់ប្តូរ និងការអនុវត្តផ្ទៃក្នុងអង្គការ។ យើងនឹងធ្វើបទបង្ហាញស្តីពី បទដ្ឋានសកលសម្រាប់គណនេយ្យភាពអង្គការសង្គមស៊ីវិល (សេចក្តីប្តេជ្ញាចិត្តទាំង១២ សកម្មភាព

សំខាន់ៗ និងសន្ទស្សន៍ដែលអាចឆ្លើយតបទៅនឹងសេចក្តីប្តេជ្ញាចិត្ត) ទៅកាន់អ្នកចូលរួម និងអោយអ្នកចូលរួមមានឱកាសពិភាក្សា និងឆ្លុះបញ្ចាំងបទដ្ឋានសកលទៅនឹងគោលនយោបាយ និងប្រព័ន្ធនៅក្នុងអង្គការរបស់គេ។

### ៣. អង្គការសង្គមស៊ីវិលអនុលោមតាមច្បាប់ស្តីពីការងារ

ច្បាប់ស្តីពីការងារត្រូវបានប្រកាសអោយប្រើដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧។ យោងទៅលើជំពូកទី១ មាត្រា១ ច្បាប់នេះអនុវត្តចំពោះសហគ្រាស ឬគ្រឹះស្ថានឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា កសិកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនាឬក្នុងសាសនាក៏ដោយ...។ ចាប់តាំងពីច្បាប់នេះត្រូវបានអនុម័ត វាត្រូវបានធ្វើវិសោធនកម្មជាច្រើនដង ហើយការធ្វើវិសោធនកម្មចុងក្រោយគឺនៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៨។ បើទោះបីជាច្បាប់នេះ ត្រូវបានអនុម័តយូរហើយក្តី ភាគច្រើនអង្គការសង្គមស៊ីវិលមិនទាន់បានយល់ដឹងនៅឡើយទេ។ ការយល់មិនច្បាស់នៃច្បាប់នេះ នាំអោយអង្គការសង្គមស៊ីវិល លំបាកអនុវត្តតាម។ អ្នកធ្វើបទបង្ហាញពីអង្គការ គ.ស.ក នឹងគូសបញ្ជាក់នូវរាល់មាត្រាទាំងឡាយណាដែលជាប់ពាក់ព័ន្ធទៅនឹងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល ព្រមទាំងពន្យល់នូវបញ្ជីត្រួតពិនិត្យដែលអាចជួយអោយអ្នកចូលរួមបានយល់ច្បាស់ពីការអនុវត្តច្បាប់ទាំងនេះ។

### ៤. អង្គការសង្គមស៊ីវិលអនុលោមតាមច្បាប់ស្តីពីសវនកម្ម និងគណនេយ្យភាព និងច្បាប់ស្តីពី អង្គការសង្គមស៊ីវិល

ក្របខណ្ឌច្បាប់ និងទំនោថ្មីៗដែលជំរុញទៅដល់ការអនុវត្តរបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា បានរុញច្រានអោយមានការព្រួយបារម្ភសម្រាប់អង្គការសង្គមស៊ីវិល។ ស្របពេលដែលការយល់ដឹងជាទូទៅរបស់អង្គការសង្គមស៊ីវិលដែលទាក់ទងទៅនឹងក្របខណ្ឌច្បាប់ទាំងនេះនៅមានកម្រិត លទ្ធភាព និងតួនាទីក្នុងកិច្ចការតស៊ូមតិ នៅតែមិនស៊ីសង្វាក់ជាមួយច្បាប់ទាំងនោះ។ ថ្មីៗនេះ ការពង្រឹងនូវការអនុវត្តច្បាប់ស្តីពី សមាគមអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសវនកម្ម និងគណនេយ្យ បានបណ្តាលអោយ មានភាពស្មុគស្មាញក្នុងកិច្ចប្រតិបត្តិការ និងបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល។

ប្រធានបទច្បាប់ទាំងពីរនេះ នឹងត្រូវបានរួមបញ្ចូលនៅក្នុងវេទិកានេះ។ វាមិនគ្រាន់តែនាំទៅដល់ការលើកកម្ពស់ការយល់ដឹង លទ្ធភាពក្នុងការអនុលោមតាមច្បាប់ប៉ុណ្ណោះទេ តែវាក៏បានជួយសម្របសម្រួលអោយមានសកម្មភាពជារួម ក្នុងចំណោមអង្គការសង្គមស៊ីវិលដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមជាប់ពាក់ព័ន្ធទៅនឹងច្បាប់ទាំងនេះ។

### ៥. សេចក្តីប្រកាសស្វែងរកឯកសារទស្សនទានសម្រាប់ជំនួយបន្តអង្គការប្រេតហ្វដឹវើល (Bfdw) និងសហភាពអឺរ៉ុប (EU)

សេចក្តីប្រកាសជំហានទី២ ស្វែងរកអង្គការសរសេរទស្សនទាន សម្រាប់ជំនួយបន្តសហភាពអឺរ៉ុប (EU) និងប្រេតហ្វដឹវើល (Bfdw)។ ជំនួយបន្តនេះ ក្រោមការគ្រប់គ្រងចាត់ចែងដោយកម្មវិធី **មូលនិធិអង្គការសង្គមស៊ីវិល** នៃអង្គការ គ.ស.ក។ ជំនួយនេះមានគោលបំណងជួយដល់អង្គការដៃគូរបស់ គ.ស.ក អង្គការដៃគូសហភាពអឺរ៉ុប(EU) អង្គការដៃគូ ប្រេតហ្វដឹវើល (Bfdw) និងអង្គការមូលដ្ឋាន រឺអង្គការបណ្តាញទាំង ១០ ដែលមានទីតាំង

ស្ថិតនៅក្នុងខេត្ត និងក្រុង (ភ្នំពេញ រតនគិរី ក្រចេះ កំពត ក្រុងព្រះសីហនុ ស្វាយរៀង សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងតាកែវ) ក្នុងន័យអភិវឌ្ឍន៍ និងប្រតិបត្តិការការងារដែលអាចអោយពួកគេមាននិរន្តរភាពហិរញ្ញវត្ថុដោយខ្លួនឯង តាមរយៈការប្រើប្រាស់យន្តការភាពជាដៃគូដែលមានបរិយាបន្នពីគ្រប់ផ្នែកផ្សេងៗ។

### គ. គោលបំណង

១. ដើម្បីប្រគល់វិញ្ញាបនបត្រជីភីភី ជូនអង្គការដែលទទួលបាននៅក្នុងឆ្នាំ២០១៨

២. ដើម្បីលើកកម្ពស់អភិបាលកិច្ច គណនេយ្យភាព និងវិជ្ជាជីវៈអង្គការសង្គមស៊ីវិល

៣. ដើម្បីជួយគាំទ្រអង្គការសង្គមស៊ីវិល ក្នុងការរៀបចំអោយមានការអនុវត្តតាម/អនុលោមតាមច្បាប់នានាដូចជាច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងច្បាប់ស្តីពីការងារ។

## II. អំពីអ្នកចូលរួម

វេទិកាស្តីពីអភិបាលកិច្ច គណនេយ្យភាព និងតម្លាភាពនេះ នឹងប្រារព្ធឡើងដោយមានអ្នកចូលរួមសរុបប្រមាណ ១០០-១២០ នាក់ ដែលអញ្ជើញមកពីអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានវិញ្ញាបនបត្រជីភីភី អង្គការដាក់ពាក្យ អង្គការដែលមានបំណងចូលរួមក្នុងប្រព័ន្ធវិញ្ញាបនបត្រជីភីភី សមាជិកអង្គការ គ.ស.ក អង្គការបណ្តាញតាមខេត្ត យុវជន ម្ចាស់មូលនិធិ និងតំណាងរាជរដ្ឋាភិបាល។

## III. ទីកន្លែង និងរបៀបវារៈ

វេទិកាស្តីពី អភិបាលកិច្ច គណនេយ្យភាព និងតម្លាភាពសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា នឹងប្រព្រឹត្តិទៅនៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១៨ នៅអគារជាយកូនៀ ទីតាំងផ្ទះលេខ ១៩-២១ ផ្លូវ ៣៣០ បឹងកេងកង III ខណ្ឌចំការមន ភ្នំពេញ។

| ម៉ោង | សកម្មភាព | វាគ្មិន និងអ្នកសម្របសម្រួល |
|---|---|---|
| ៧:៣០-០៨:១៥ | ការចុះឈ្មោះអ្នកចូលរួម | **លោក គឹម សេរីនាថ**<br>ជំនួយការកម្មវិធីអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ អង្គការ គ.ស.ក |
| ០៨:១៥-០៨:២៥ | • គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា | **ទាំងអស់គ្នា** |

| | | |
|---|---|---|
| | • ការបង្ហាញជូនពីគោលបំណង និងរបៀបវារៈនៃកម្មវិធី | **លោក ជា វិបុល**<br>**អ្នកស្រី តួ ចាន់ដារ៉ា**<br>អ្នកឯកទេស ផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ អង្គការ គ.ស.ក |
| | • ការសំដែងរបាំជូនពរ | សំដែងដោយក្រុមយុវជនអង្គការ **សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម** |
| **ពិធីប្រគល់វិញ្ញាបនបត្រ** | | |
| ០៨:២៥-១០:០០ | **<u>វគ្គទី១: សន្ទរកថា និងកម្មវធីប្រគល់វញ្ញាបនបត្រ</u>** | |
| | ❖ កិច្ចស្វាគមន៍ និងការធ្វើបច្ចុប្បន្នភាពនៃប្រព័ន្ធវិញ្ញាបនបត្រជីភីភី | **លោកសៀង សារឿន**<br>នាយកប្រតិបត្តិអង្គការ គ.ស.ក |
| | ❖ **សុន្ទរកថាបើកកម្មវធី** | **ឯកឧត្តម ឱ ច័ន្ទ្រផល**<br>**រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ** |
| | ❖ វីដេអូសង្ខេបអំពីអង្គការដែលទទួលបានវិញ្ញាបនបត្រជីភីភីក្នុងឆ្នាំ២០១៨ | **លោក ឈូក ផលពុទ្ធិឫទ្ធិ៍**<br>អ្នកឯកទេសផ្នែកទំនាក់ទនងអង្គការ គ.ស.ក |
| | ❖ ការសំដែងរបាំឆៃយាំ | សំដែងដោយក្រុមយុវជនអង្គការ **សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម** |

| | | |
|---|---|---|
| | ❖ កម្មវិធីប្រគល់វិញ្ញាបនបត្រជូនអង្គការដែលទទួលបានក្នុងឆ្នាំ២០១៨<br><br>១. អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO)- ទទួលវិញ្ញាបនបត្រលើកទី៣<br>២. អង្គការវី អេស អូ (VSO)-ទទួលវិញ្ញាបនបត្រលើកទី២<br>៣.អង្គការជីវិតនៅកម្ពុជា(TLC)-ទទួលវិញ្ញាបនបត្រលើកទី២<br>៤.អង្គការលើកកម្ពស់យុវជន (PEPY)-ទទួលវិញ្ញាបនបត្រលើកទី១<br>៥.អង្គការបណ្តុះកុមារ (BK)-ទទួលវិញ្ញាបនបត្រ<br><br>៦.អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)-ទទួលបានវិញ្ញាបនបត្រលើកទី៤ | ក្រោមអធិបតីភាព<br>**ឯកឧត្តម ងី ច័ន្ទផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ<br><br>**លោក គេង ម៉ិនឈឿត**<br>**សមាជិកគណៈកម្មាធិការអនុវត្តក្រុម** |
| | ❖ ចំណាប់អារម្មណ៍របស់អង្គការដែលទទួលបានវិញ្ញាបនបត្រ | **សម្របសម្រួលដោយ**<br>**អ្នកស្រី ស៊ិន ពុទ្ធារី**<br>ប្រធានផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍សមាជិកភាពអង្គការ គ.ស.ក |
| | ❖ ជូនសៀវភៅ ប៊ិច និងបាច់ផ្កាអនុស្សាវរីយ៍ជូនគណៈអធិបតី និងថតរូបជាក្រុម | **អ្នកស្រី ស៊ិន ពុទ្ធារី**<br>ប្រធានផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍សមាជិកភាពអង្គការ គ.ស.ក |
| ១០:00-១០:២០ | ទស្សនាពិព័ណ៌របស់អង្គការទទួលបានវិញ្ញាបនបត្រ និងសម្រាកពិសារអាហារសម្រន់ | អ្នកចូលរួមទាំងអស់គ្នា |
| ១០:២០-១១:៣០ | **វគ្គទី២: បទដ្ឋានសកលស្តីពីគណនេយ្យភាព សម្រាប់អង្គការសង្គមស៊ីវិល**<br>• សវតាស្តីពីបទដ្ឋានសកល<br>• ភាពជាប់ពាក់ព័ន្ធរវាងបទដ្ឋានសកល និងបទដ្ឋានជីភីភី<br>• គោលបំណងរបស់បទដ្ឋានសកល | **លោក ជា វិបុល**<br>អ្នកឯកទេស ផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ អង្គការ គ.ស.ក |

| | | |
|---|---|---|
| | • សេចក្តីប្តេជ្ញាចិត្តទាំង១២ និងសកម្មភាពសំខាន់ៗ | |
| ១១:៣០-១២:០០ | **<u>វគ្គទី៣: អង្គការសង្គមស៊ីវិលអនុលោមតាមច្បាប់ដែលទើបបានអនុម័តថ្មីៗ</u>**<br>• ចំនុចសំខាន់ៗនៅក្នុងច្បាប់ស្តីពីសវនកម្ម និងគណនេយ្យ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសមាគម អង្គការមិនមែនរដ្ឋាភិបាល។<br>• ការសិក្សាលើបញ្ជីត្រួតពិនិត្យ ច្បាប់ស្តីពីសវនកម្ម និងគណនេយ្យ ច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ | **លោក កៅ ឌីណា**<br>ប្រធានកម្មវិធីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា<br><br>**លោក យឿង សុធារ៉ា**<br>ប្រធានផ្នែកតស៊ូមតិ និងបណ្តាញ |
| ១២:០០-០១:៣០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១:៣០-៣:៣០ | បន្តវគ្គទី៣<br>**<u>អង្គការសង្គមស៊ីវិលអនុលោមតាមច្បាប់ដែលទើបបានអនុម័តថ្មីៗ</u>**<br>• ចំនុចសំខាន់ៗនៅក្នុងច្បាប់ស្តីពីសវនកម្ម និងគណនេយ្យ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសមាគម អង្គការមិនមែនរដ្ឋាភិបាល។<br>• ការសិក្សាលើបញ្ជីត្រួតពិនិត្យ ច្បាប់ស្តីពីសវនកម្ម និងគណនេយ្យ ច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ | **លោក កៅ ឌីណា**<br>ប្រធានកម្មវិធីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា<br><br>**លោក យឿង សុធារ៉ា**<br>ប្រធានផ្នែកតស៊ូមតិ និងបណ្តាញ |
| ៣:៣០-៣:៤៥ | សម្រាកអាហារសម្រន់ | ទាំងអស់គ្នា |
| ៣:៤៥-៤:១៥ | **<u>វគ្គទី៤: សេចក្តីប្រកាសស្វែងរកឯកសារទស្សនទានសម្រាប់ជំនួយបន្តអង្គការប្រេតហ្វដឺវេល (Bfdw) និងសហភាពអឺរ៉ុប (EU)</u>**<br>• សេចក្តីប្រកាសជំហានទី២ | **លោក នង នាថនរៈ**<br>ប្រធានផ្នែកគៀរគរធនធាន |
| ៤:១៥-៤:២០ | វាយតម្លៃកម្មវិធី | **លោក គឹម សេរីនាថ**<br>ជំនួយការកម្មវិធីអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ |

| | | |
|---|---|---|
| ៤:២០-៤:៣០ | សុន្ទរកថាបិទកម្មវិធី | **លោកសឿង សារឿន**<br>នាយកប្រតិបត្តិអង្គការ គ.ស.ក |

☞ *អង្គការ គ.ស.ក សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈដោយផ្អែកលើការចូលរួមរបស់វាគ្មិន និងពេលវេលាជាក់ស្តែង។*